**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**របាយការណ៍សង្ខេប**

**អង្គវិបស្សនាស្តីពី**

**ការពិនិត្យវឌ្ឍនភាពនៃប្រព័ន្ធក្រុមការងារបច្ចេកទេសចម្រុះ**

**ថ្ងៃទី ០៨-០៩ ខែមេសា ឆ្នាំ ២០១០**

**សណ្ឋាគារ អប្សរាអង្គរ ខេត្តសៀមរាប**

គណៈកម្មាការពិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(គ.ជ.នា/ក.អ.ក) បានរៀបចំសិក្ខាសាលាស្តីពី "ការពិនិត្យវឌ្ឍនភាពនៃប្រព័ន្ធក្រុមការងារបច្ចេកទេសចម្រុះ" រយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ នៅខេត្តសៀមរាប ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈឿង យ៉ាវណារ៉** អគ្គលេខាធិការ គ.ជ.នា/ក.អ.ក តាមរបៀបវារៈដែលមានគ្រោងទុកដូចដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១ ។ លើសពីនោះ មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ដែលជាប្រធាន និងមន្ត្រីលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះទាំង១៩ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជាផងដែរ ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមប្រធាន** បានថ្លែងសន្ទរកថាស្វាគមន៍ ឯកឧត្តម លោកជំទាវ និងមន្ត្រីតំណាងក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ តំណាងអង្គការ JICA និង UNDP និងមន្ត្រីគ.ជ.នា/ក.អ.ក ទាំងអស់ដែលមានវត្តមាននៅក្នុងអង្គវិបស្សនា ។ គោលបំណងនៃអង្គវិបស្សនា គឺដើម្បីពិភាក្សាអំពីដំណើរការរៀបចំវេទិកាកិច្ចសហ-ប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ការពិនិត្យនិងវាយតម្លៃឡើងវិញអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តន៍ការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ព្រមទាំងការកំណត់អាទិភាពសម្រាប់អនុវត្តន៍ការងារនាពេលបន្ទាប់ ។ **ឯកឧត្តមប្រធាន** ក៏បានលើកផងដែរអំពីការងារជាគន្លឹះមួយចំនួន ពមទាំងទិសដៅផែនការការងារសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ ។

ដូចដែលបានគ្រោងទុក អង្គវិបស្សនាបានដំណើរការតាមរបៀបវារៈនិងមានខ្លឹមសារសង្ខេបដូចខាងក្រោម :

***<u>របៀបវារៈទី១:</u>*** ***ការពិនិត្យលើលទ្ធផលនៃសេចក្តីព្រាងរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាឆ្នាំ ២០១០***

លោក **រស់ សាលីន** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានគោលនយោបាយ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ គ.ជ.នា/ក.អ.ក បានធ្វើបទបង្ហាញពីរបកគំហើញនិងលទ្ធផលសង្ខេបនៃរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ២០១០ ក៏ដូចជាដំណើរការ និងការរៀបចំការវាយតម្លៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសដំណាក់កាលទីពីរ ដែលរៀបចំឡើងដោយ គ.ជ.នា/ក.អ.ក (បទបង្ហាញនេះមានភ្ជាប់នៅក្នុងឧប-សម្ព័ន្ធ ទី២) ។ ជារួមអង្គវិបស្សនាបានសម្តែងនូវការគាំទ្រ និងកោតសរសើរពីកិច្ចខិតខំប្រឹងប្រែងរបស់ គ.ជ.នា/ក.អ.ក

ដែលបានរៀបចំរបាយការណ៍នេះឡើង ។ លើសពីនេះ ក្នុងការពង្រឹងហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ **ឯកឧត្តមប្រធាន** បានលើកឡើងថា គ.ជ.ន/ក.អ.ក នឹងគាំទ្រក្នុងការកែលម្អបន្ថែមនូវប្រព័ន្ធត្រួតពិនិត្យ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា (Cambodia ODA Database) តាមការស្នើសុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

***<u>របៀបវារៈទី២:</u> ពិនិត្យលើសូចនាករតាមដានរួមគ្នាថ្មី ដែលនឹងដាក់ជូនក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ដើម្បីពិនិត្យ និងអនុម័ត***

លោកស្រី **ហ៊ាង កាណែល** អ្នកជំនាញការថ្នាក់ជាតិនៃ គ.ជ.ន/ក.អ.ក បានធ្វើបទបង្ហាញលើរបៀបវារៈទីពីរនេះ ដោយសង្កត់ធ្ងន់លើដំណើរការ និងការរៀបចំសូចនាករតាមដានរួមគ្នាថ្មីនេះ ជាពិសេសការពិភាក្សាលើខ្លឹមសារនៃការបកប្រែជាភាសាខ្មែរ (បទបង្ហាញនេះមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៣) ។ ជាលទ្ធផល អង្គសិក្ខាសាលាទាំងមូលបានឯកភាពស្ទើរតែទាំងស្រុងលើខ្លឹមសារ ក៏ដូចជាការបកប្រែជាភាសាខ្មែរលើរបាយការណ៍នេះ ដោយគ្រាន់តែតម្រូវឱ្យមានការកែលម្អបន្ថែមលើពាក្យពេចន៍បច្ចេកទេសមួយចំនួនប៉ុណ្ណោះ ។ បន្ថែមលើនោះ **ឯកឧត្តមប្រធាន** បានស្នើអោយក្រុមការងារត្រូវប្រកាន់ជំហរភាពជាម្ចាស់ និងភាពដឹកនាំ ដើម្បីរក្សាអោយបាននូវតម្លៃលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះ ករណីមានការស្នើសុំកែសម្រួលសូចនាករពីសំណាក់ដៃគូអភិវឌ្ឍន៍ ។

***<u>របៀបវារៈទី៣:</u> ការពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាពក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កម្ពុជាលើកទី២***

លោក **ជូ ហេង** ទីប្រឹក្សាគោលនយោបាយជាន់ខ្ពស់នៃ គ.ជ.ន/ក.អ.ក បានធ្វើបទបង្ហាញស្តីពី របាយការណ៍វឌ្ឍនភាពបូកសរុបនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាពក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើក ទី២ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៤) ដោយផ្តោតជាសំខាន់លើវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នានេះ ចាប់តាំងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ នាខែធ្នូ ឆ្នាំ ២០០៩ កន្លងមក ។ ជាលទ្ធផល អង្គវិបស្សនាទាំងមូលបានឯកភាពភាគច្រើនលើខ្លឹមសារ ក៏ដូចជាការបកប្រែជាភាសាខ្មែរលើរបាយការណ៍នេះ ដោយគ្រាន់តែមានការកែសម្រួលលើកង្វះខាតបន្តិចបន្តួចប៉ុណ្ណោះ ។

***<u>របៀបវារៈទី ៤:</u> ការតាមដានត្រួតពិនិត្យលើប្រធានបទស្តីពី ផែនការយុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និងការ ធ្វើសុខដុមនីយកម្មរវាងការងារ ផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងការ រៀបចំចំណាយប្រតិបត្តិការអាទិភាព (Priority Operation Cost)***

តំណាងក្រសួងផែនការ បានធ្វើបទបង្ហាញស្តីពី ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និងការធ្វើសុខដុមនីយកម្មរវាងការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៥ ។ លើសពីនោះ ឯកឧត្តម **ឈួន ឆាម** អគ្គលេខាធិការរង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងជាអនុប្រធានក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ ក៏បានចូលរួមធ្វើបទបង្ហាញមួយដែលទាក់ទងទៅនឹងទស្សនទាន ក៏ដូចជាជំហររបស់រាជរដ្ឋាភិបាល លើការរៀបចំអោយមាន

ទម្រង់ថ្មីនៃការផ្តល់ប្រាក់លាភការបន្ថែម ហៅថា ***ចំណាយប្រតិបត្តិការអាទិភាព*** **(Priority Operation Cost)** ដែលមានចរិកជាចំណាយបណ្តោះអាសន្ន ហើយនឹងបញ្ចប់ទៅវិញនៅពេលដែលគម្រោង រឺផែនការនោះបានបញ្ចប់ (បទបង្ហាញ នេះមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៦) ។ ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ដែលធ្វើបទបង្ហាញដោយតំណាងក្រសួងផែនការ ក្នុងវេទិការកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣ **ឯកឧត្តមប្រធាន** បានស្នើឱ្យក្រសួងផែនការពិនិត្យឡើងវិញ លើខ្លឹមសារ និងបែបបទនៃរបាយការណ៍ម្តងទៀត ដោយសារ បទបង្ហាញពុំបានរំលេចពីវឌ្ឍនភាពជាក់លាក់ណាមួយ ដូចដែលមានចែងនៅក្នុងគោលដៅទាំងបីនៃ ការរៀបចំផែនការយុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ។ ហើយឯកឧត្តម ក៏បានស្នើអោយក្រុមប្រឹក្សាកំណែទម្រង់ រដ្ឋបាល ខិតខំពន្លឿនការរៀបចំគោលការណ៍ដើម្បីអនុវត្ត ***ចំណាយប្រតិបត្តិការអាទិភាព*** នេះអោយបានឆាប់ ។

***<u>របៀបវារៈទី៥:</u> ការផ្លាស់ប្តូរបទពិសោធន៍រវាងក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីការកំណត់វឌ្ឍនភាព និងបញ្ហាប្រឈមនៃអាទិភាពហិរញ្ញប្បទានសហប្រតិបត្តិការ ការបង្កើនប្រសិទ្ធភាពភាពជាដៃគូ និងការពង្រឹងបន្ថែមនូវប្រសិទ្ធភាព ក្នុងការអនុវត្តន៍ការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យនិមួយៗ***

អង្គវិបស្សនាបានលើកយកផ្នែកសំខាន់ចំនួនបី មកធ្វើការពិភាក្សា ដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាងក្រុមការងារបច្ចេកទេសចម្រុះ ពោលគឺការកំណត់វឌ្ឍនភាព និងបញ្ហាប្រឈមនៃអាទិភាពហិរញ្ញប្បទានសហប្រតិបត្តិការ ការបង្កើនប្រសិទ្ធភាពភាពជាដៃគូ និងការពង្រឹងបន្ថែមនូវប្រសិទ្ធភាព ក្នុងការអនុវត្តន៍ការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យនិមួយៗ ។ បន្ទាប់ពីកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ទៅតាមកម្រង ក៏ដូចជានៅអង្គប្រជុំធំ អង្គវិបស្សនាកំណត់បាននូវបញ្ហាប្រឈមចំនួន៤ ដែលក្រុមការងារបច្ចេកទេសចម្រុះជួបប្រទះដែលរួមមាន ÷

ក) កង្វះខាតខាងធនធាន (ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ)

ខ) ការរៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

គ) ការបង្កើនប្រសិទ្ធភាព ភាពជាដៃគូតាមវិស័យនៅមានកម្រិត

ឃ)ការយល់ដឹងមានកម្រិត អំពីទស្សនទាន និងដំណើរការនៃអភិក្រមគ្រប់គ្រងតាមវិស័យ និងអភិក្រមគ្រប់គ្រងតាមកម្មវិធី (SWAp/SWiM/PBAs etc)

**ឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ ឯកឧត្តមប្រធានបានផ្តល់ជាអនុសាសន៍និងដំណោះស្រាយដូចខាងក្រោម ÷**

១) គ.ជ.នា/ក.អ.ក នឹងបន្តគាំទ្រដំណើរការលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះដែលបានស្នើសុំ តែមានការកែសម្រួលខ្លះលើនីតិវិធីនៃការគាំទ្រ ដោយធ្វើឡើងក្នុងរូបភាពជាអាដហុក ពោលគឺធ្វើឡើងទៅតាមសំណើនិមួយៗ ។ លើសពីនោះ តម្រូវអោយលេខាធិការដ្ឋានត្រូវគិតគូពីគម្រោងចំណាយជាមុនដើម្បីអោយ គ.ជ.នា/ក.អ.ក រៀបចំវិភាជថវិកាទៅតាមគម្រោងចំណាយនោះ ។

២) គ.ជ.នា /ក.អ.ក អាចផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ការតាមដាន និងវាយតម្លៃនៅត្រឹមតែកម្រិតគម្រោង រឺកម្មវិធីប៉ុណ្ណោះ ដែលក្នុងនោះក្រុមការងារ អាចស្នើរមក គ.ជ.នា/ក.អ.ក តាមរយៈលោកស្រី Misa Fukunagha ទីប្រឹក្សាប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការរបស់អង្គការ JICA ប្រចាំ គ.ជ.នា/ក.អ.ក ដែលទទួលបន្ទុកក្នុងវគ្គបណ្តុះបណ្តាលជំនាញខាងលើនេះ ។

៣)	ទាមទារឱ្យក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យនិមួយៗ បន្តសហការ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានកម្មវិធី និងវប្បធម៌ចម្រុះ ក្នុងគោលបំណងធ្វើការរួមគ្នាដើម្បីឆ្ពោះទៅរកគោលដៅរួម ។

៤) គ.ជ.ទ/ក.អ.ក នៅតែបន្តផ្តល់ការបណ្តុះបណ្តាល ក៏ដូចជាការចែករំលែកព័ត៌មាន និងបទពិសោធន៍ស្តីពីទស្សនទាន និងដំណើរការនៃអភិក្រមគ្រប់គ្រងតាមវិស័យ និងអភិក្រមគ្រប់គ្រងតាមកម្មវិធី ទៅតាមសំណូមពររបស់ក្រុមការងារ ។

ក្នុងឱកាសបិទអង្គវិបស្សនា ឯកឧត្តមប្រធាន បានធ្វើការបូកសរុបលទ្ធផលការងារ ដែលសម្រេចបានក្នុងរយៈពេលពីរថ្ងៃកន្លងមក ជាពិសេសថ្លែងអំណរគុណសម្រាប់ការចូលរួមផ្តល់ជាធាតុចូលដ៏សំខាន់ ពីសំណាក់ឯកឧត្តម លោកជំទាវ និងលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសចម្រុះ និងអ្នកដែលមានវត្តមានក្នុងអង្គសិក្ខាសាលាទាំងអស់ ។

អង្គសិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ៥:០០ នាទីល្ងាច នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ ក្រោមបរិយាកាសសប្បាយរីករាយ និង យោគយល់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

**រៀបចំដោយនាយកដ្ឋានគោលនយោបាយ**
**និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ**